កំរងរឿង: ឧបសំរាប់ពនាក់



ីរបស់បង្គួយ

SIPAR

០៨០.
២៨០

www.budinst.gov.kh www.elibraryofcambodia.org

ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

មន្ទីរអប់រំ ខេត្តព្រៃវែង

# រឿង ខួរសំរាប់ពានាក់



អ្នករៀបរៀង: ឥស្សរី យ៉ាត

គូរដោយ: ប៉ុល សារឿន

www.budinst.gov.kh www.elibraryofcambodia.org

រឿង

# រូបសំរាប់ ៣ នាក់



បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៦៦/៩៤

## អានច្រើន ចេះច្រើន

www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

នៅសម័យកាលដែលលើផែនដីយើងនេះ មានសុទ្ធតែព្រៃ សត្វទាំងអស់បានរស់នៅក្នុងខ្ទមរៀង១ខ្លួន ។ ខ្ទមទាំងនោះធ្វើអំពីកូនឈើ ប្រក់ស្បូវ សង់ក្នុងព្រៃ រឺនៅតាមទីវាល ។

ពួកសត្វទាំងនោះរស់នៅយ៉ាងសប្បាយ គ្មាននរណាម្នាក់មានជំលោះនឹងគ្នាឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃនេះ ខ្លាល្អុងបានវង្វេងពេញតែព្រៃ ។ ជាច្រើនយប់មកហើយ វាដេកកណ្ដាលវាល ហាលទឹកសន្សើម ។ វាគិតថា បើសង់បានខ្ទមមួយនោះវានឹងស្រួលជាងនេះ ។ វាក៏សំរេចថានឹងសង់ខ្ទមមួយដូចគេដូចឯង ។ វាដើររកកន្លែងយ៉ាងយូរ ទីបំផុតវារកឃើញ កន្លែងមួយនៅមាត់ព្រៃ ។ គឺជាកូនវាលតូចមួយ មានដើមឈើធំៗជាម្លប់ ។ ជាកន្លែងត្រជាក់ស្រួលគួរជាទីមនោរម្យ ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ជាដំបូងត្រូវកាត់ស្មៅខ្ពស់ៗទាំងនេះ ។ គិតដូចនេះ វាក៏ទៅរកកណ្តៀវ ។

ពាំពែឈ្មោល ពេលដើរកាត់ទីនោះ វាមានគំនិតដូចខ្លាឃ្មុំដែរ

- អាំ ! នេះជាកន្លែងដែលគួររស់នៅ !

គិតភ្លាមធ្វើភ្លាម ។ ពាំពែឈ្មោលយកកណ្តៀវវាច្រូតស្មៅនោះអស់មួយវាល ល្មមសង់បានកូនខ្ទម ។ រួចវាក៏ទៅរកស៊ីបាត់ទៅ ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ស្អែកឡើង ខ្លាល្មុងកាន់កណ្ដៀវមកពីព្រលឹម ។ វាភ្ញាក់ជាខ្លាំង ដោយឃើញស្មៅត្រូវបានច្រូតរួចស្រេច វាគិតថាប្រហែលជាទេវតា រក្សាពួកខ្លាល្មុងជួយវាហើយ ។

- ស្អែកអញនឹងមកសំរួចបង្គោល !

វានិយាយម្នាក់ឯងខ្លាំងៗ អោយទេវតាឮ ។ បន្ទាប់មកវាក៏ទៅរកចំណីអាហារបាត់ទៅ ។



www.budinst.gov.kh www.elibraryofcambodia.org




www.budinst.gov.kh www.elibraryofcambodia.org

ពេលរសៀលនោះ ពពែឈ្មោលមកដល់ ។ ពពែឈ្មោល ទៅកាប់បង្គោល និងសំរូច រួចជាស្រេចយកមកគរទុក នៅលើ ទីលានសំណង់នោះ ។ បន្ទាប់មកវា ទៅរកស៊ីស្មៅបាត់ទៅ ។

ព្រឹកស្អែក ខ្លាល្ងង់មកដល់ ។ វាឃើញបង្គោលសំរូច រួចស្រេច សំរាប់សង់ខ្ទម ។ វាឆ្ងល់យ៉ាងខ្លាំង ។

- ស្អែកអញនឹងដាំបង្គោលទាំងនេះ ! ។ វាថាខ្លាំងៗ ដើម្បីអោយទេវតាដែលនៅពូនក្បែរនោះឮ ។ បន្ទាប់មកវាក៏ចាក ចេញទៅរកអាហារដូចមុនៗទៀត ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ពេលរសៀល ពពែឈ្មោលត្រឡប់មកកន្លែងសំណង់នោះទៀត ។ វាជីករណ្ដៅ រួចដាំបង្គោលទាំងនោះ ។ វាចងផ្ដោង ផ្ដានសំរាប់ដំបូលរួចជាស្រេច ។ ហើយវាក៏ទៅរកស៊ីបាត់ទៅ ។

នៅព្រឹកថ្ងៃទី ៤ ខ្លាល្មុងមកដល់ការដ្ឋាន ។ វាឃើញខ្ទមវាជិតហើយ គឺនៅតែប្រក់ដំបូលទៀតទេ ។ វាសប្បាយណាស់លោតហក់កញ្ជ្រោលពេញវាល ។

- ទេវតានេះជា ឱពុកខ្ញុំហើយ ! ស្អែកខ្ញុំមកប្រក់ដំបូលបង្ហើយ ។ វានិយាយខ្លាំងៗ ។ រួចវាក៏ទៅរកអាហារបាត់ទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

ពេលរសៀលនោះ ពពៃបានមកប្រក់ដំបូលខ្ទមយ៉ាងស្អាត ។ ប្រក់ហើយវាអង្គុយមើលយ៉ាងពេញចិត្ត ហើយវាក៏ទៅស៊ីស្មៅបាត់ទៅ ។

ថ្ងៃទី ៥ ពេលព្រឹក ខ្លាល្មុងមកទៀត ។ វាឃើញខ្ទមវាហើយស្រេច ។ វាសែនសប្បាយចិត្ត ។ វាគិតថា ថ្ងៃស្អែកអញមកនៅហើយ ។

ខ្លាល្មុងបន្ទាប់ពីដើរគយគន់ ខ្ទមអស់ចិត្តហើយវាក៏ទៅរកអាហារបាត់ទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

ស្អែកឡើង ខ្លាល្ងង់បានស្ពាយឥវ៉ាន់សំពីងសំពោងមកកាន់ខ្ទមរបស់គេ ។ វាភ្ញាក់យ៉ាងខ្លាំង ដោយឃើញពពែឈ្មោលពពែញីបាននៅក្នុងផ្ទះនោះរួចជាស្រេច ។

- តើឯងធ្វើអ្វីក្នុងផ្ទះអញនេះ ? (ខ្លាគ្រហឹមសំឡុត)

- នេះ រឺផ្ទះឯង ? វាជាផ្ទះអញទេសំលាញ់ !

ពពែបានរៀបរាប់ប្រាប់ខ្លាពីសកម្មភាពវាតាំងពីច្រូតស្មៅរហូតដល់សង់ ផ្ទះហើយស្រេច ។

- មិនមែនទេ ! មិនមែនទេ ! (ខ្លាគ្រហឹម) គឺទេវតារបស់ខ្លាទេ ដែលសង់ផ្ទះនេះ ។

- និយាយតែផ្តាស ! គឺខ្ញុំទេដែលសង់ផ្ទះនេះ ! ខ្ញុំសង់តែម្នាក់ឯងគត់ !



www.budinst.gov.kh www.elibraryofcambodia.org




www.budinst.gov.kh www.elibraryofcambodia.org

ពេលនោះ ខ្លាល្អុងបានដំឡើងសំលេង ឯពពែក៏បន្លឺងបំពង់ក ដែរ ។ ពពែញី ឃើញសភាពការណ៍នេះមិនល្អ ក៏ធ្វើអន្តរាគមន៍ :

- ខ្មួមយើងទូលាយដែរ ! យើងចែកគ្នានៅទៅ ! យើងអាចនៅ ៣ នាក់ក៏បាន ។

ចាប់ពីថ្ងៃនោះមកម្នាក់ៗធ្វើការតាមសមត្ថភាពជំនាញ រៀងៗខ្លួន ។ ខ្លាល្អុងចាប់កូនសត្វយកមកផ្ទះ ឯពពែឈ្មោល ដើររកបន្លែបង្ការ ។ ពពែញីអ្នកដាំស្លនៅផ្ទះ ។

តើសភាពការណ៍នេះឋិតឋេរទេ ?

នរណាដឹង ?


www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃមួយនោះ ខ្លាល្មងរកចាប់កូនសត្វមិនបាន ។ វាបានលបចូលភូមិអ្នកស្រុក រួចចាប់សំលាប់បានពពែញីមួយ ។ វាយកមកដល់ខ្ទម ។

ពពែភ្ញាក់ព្រើត ! ពពែញី ? នេះជាការក្បត់កិច្ចសន្យារបស់ខ្លាល្មង ។

- យើងមិនដែលស៊ីសាច់ សត្វនេះទេ មិត្តអើយ !.



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ពពែឈ្មោលបានចេញពីផ្ទះ ។ វាទៅរកអ្នកខ្លាំងក្នុងព្រៃនោះអោយជួយ រកសំលាប់ខ្លាល្ងង់អោយវាមួយក្បាល ។ ពេលបានហើយវាក៏យកខ្មោចខ្លាល្ងង់ទៅទំលាក់នៅមុខខ្ទម ។ ខ្លាល្ងង់បានឃើញ វាតក់ស្លុតយ៉ាងខ្លាំង ។ វាថា :

- មិត្តអើយ ! ខ្ញុំពុំដែលស៊ីសាច់សត្វប្រភេទនេះទេ !

ខ្លាល្ងង់ចាប់ផ្ដើមភ័យព្រួយ ។ វាគិតថា ចុះអាពពែនេះវាសំលាប់ខ្លាល្ងង់តាមវិធីណា ?



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ពេលពពែឈ្មោលចេញបាត់ ខ្លាបានលបសួរពពែញី ពីរបៀបសំលាប់ខ្លា របស់ពពែឈ្មោល ។

- សំលាញ់អើយ ! ប្តីខ្ញុំមានភ្នែកជាធ្នូ ។ កាលណាគាត់ស្អប់អ្នកណាម្នាក់ គាត់ថតអ្នកនោះចូលក្នុងភ្នែកគាត់ ។ មិនយូរប៉ុន្មានព្រលឹងអ្នកនោះនឹងចេញពីខ្លួន អ្នកនោះហើយ ។

ដូចនេះហើយបានជាគាត់សំលាប់ខ្លាល្អុងនេះបាន ។ វាជាការសំងាត់របស់គាត់ ។ សូមកុំប្រាប់នរណាអោយសោះណា ! ប្រយ័ត្នគាត់ដឹង ។

LIBRARY
BUDDHIST INSTITUTE



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ខ្លាល្ងង់ចាប់ផ្ដើមភ័យព្រួយ ។ វាញ័រដៃញ័រជើងហើយក៏បែរបន់ថា :

- ឱទេវតារក្សាខ្លាល្ងង់អើយ ! សូមជួយខ្ញុំផង ! សូមកុំអោយពពែឈ្មោលថតខ្ញុំបាន ! ខ្ញុំសូមអង្វរ !

ទេវតាហាក់ដូចជាគ្មានឮពាក្យអង្វររបស់ខ្លាល្ងង់សោះ ។ ខ្លាចេះតែនឹកថា :

- "បើវាមកវិញ ! វាសំលឹងអញ ! វាថតអញ ! អញនឹងបាត់ព្រលឹង ! អញនឹងងាប់"



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

គតសព្វគតគ្រប់ខ្លាល្ហុងបានលា មេពពែ រួចក៏បោលចូលព្រៃបាត់ទៅ ។ គឺចាប់ពីពេលនោះមក ហើយ ដែលខ្លាល្ហុងរស់នៅតែក្នុងព្រៃជ្រៅៗក្រាស់ៗ ។ ឯពពែរស់នៅតែជាមួយមនុស្ស ព្រោះវាយល់ថា ពុំមានគ្រោះថ្នាក់ដល់វា ។

តាមលំនាំរឿងរបស់

**"មជ្ឈិមបុរី"**



* ខ្លាល្ហុង (leopard) វារស់នៅតំបន់អាហ្វ្រិច និងនៅអាស៊ីផងដែរ វារស់នៅក្នុងព្រៃជ្រៅៗ ហើយវាពូកែលាក់ខ្លួនណាស់ ។ វាជាសត្វស៊ីសាច់ជាអាហារ ហើយមានកំលាំងដ៏លើសលុប ។



www.elibraryofcambodia.org

កាលពីមុនមានព្រះច័ន្ទជាច្រើន ច្រើនរាប់មិនអស់ ។ ពួកសត្វមានជីវិតទាំងអស់មានស្ថានភាពដូចខ្យល់ដូច្នេះដែរ ។ គេដើតនៅគ្រប់ទីកន្លែង សូម្បីគ្រាន់តែមានខ្យល់ជំនោររំពែបន្តិចក៏ដោយ ។ ខ្លះហើរទៅកន្លែងនេះ ខ្លះពោងឡើងកន្លែងនោះ គេធ្វើចលនាគ្មានឈប់ឈរ ។

ពេលណាគេចង់ឈប់នៅកន្លែងណាមួយនោះ អោយបានយូរបន្តិច នោះគេនឹងត្រូវរុញច្រានពីអ្នកដទៃ អោយខ្ទាតចេញពីទីនោះភ្លាមមួយរំពេច ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org





ព្រះឥន្ទ្រាបានបើកទិព្វចក្ខុ មើលមកសត្វលោកលើផែនដី ។ ឃើញយ៉ាងនេះព្រះឥន្ទ្រាក៏បានកោះប្រជុំពួកសត្វនៅលើផែនដី និងនៅក្នុងមេឃទាំងអស់ ។ ព្រះឥន្ទ្រាមានព្រះបន្ទូលថា :

-សត្វលោកទាំងអស់ រស់នៅដូចខ្យល់ព្យុះ ក្បាលចុះក្រោម គ្មានកន្លែងដេក គ្មានកន្លែងហូបចុក គ្មានកន្លែងលេងសប្បាយ ។ យើងចង់អោយម្នាក់ៗ មានលំនៅដ្ឋានច្បាស់លាស់ នៅលើផែនដី រឺនៅក្នុងមេឃ ។





www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ពួកមនុស្ស និងពួកសត្វយល់ព្រមតាមគំនិតព្រះឥន្ទ្រា ។ ព្រោះពួកគេបានធ្វើចលនា ឆ្វេកឆ្វាចពេញមេឃ ពេញដីជាយូរលង់មកហើយ ។

- និយាយមកមើល ! តើពួកឯងចង់នៅឯណា ? ព្រះឥន្ទ្រាសួរទៅពួកមនុស្ស ។

- យើងខ្ញុំចង់បានផ្ទះ និងដីស្រែចំការ !....

ព្រះឥន្ទ្រាងើបព្រះកេសរួចញញឹម ហើយតបថា ៖

- ពួកឯងនឹងសំរេចតាមបំណងរបស់ឯង !....



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ពួកសត្វផ្សេងៗបានបន្តកន្ទុយគ្នាចូលគាល់ព្រះឥន្ទ្រា ៖

- ខ្ញុំចង់រស់នៅក្នុងអាកាស !

- ខ្ញុំចង់រស់នៅក្នុងព្រៃស៊ុបទ្រុប !

- ខ្ញុំចង់រស់នៅក្នុងដី !

ពួកគេខ្លះចង់រស់នៅក្នុងព្រៃ ខ្លះក្នុងត្រើប ខ្លះក្នុងទឹកទន្លេ បឹង ត្រពាំង ខ្លះទៀតចង់រស់នៅក្នុងជ្រោះ ក្នុងអណ្តូងជ្រៅៗ ប្លែកពីគ្នាតាមចំណូលចិត្តរបស់ពួកគេ ។

ព្រះឥន្ទ្រាថា ៖

- សូមសំរេចតាមបំណងរៀងៗខ្លួនចុះ ព្រោះផែនដី និងមេឃធំធេង ល្វឹងល្វើយណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

នាឱកាសនោះម្នាក់ៗ បានសុំតាមចំណូលចិត្តរបស់ពួកគេ ។ ប៉ុន្តែក្នុងចំណោមសត្វទាំងនោះ សត្វបង្កួយនៅស្ងៀមគ្មានស្តីមួយម៉ាត់ ។ ព្រះឥន្ទ្រានឹកឆ្ងល់ជាខ្លាំង ។ ព្រះអង្គក៏សួរថា : - បង្កួយ ! ឯងមិនរើសកន្លែងរស់នៅនឹងគេទេវឺ ?

បង្កួយហាក់ដូចជាស្ទាក់ស្ទើរ ។ វាក៏បន្លឺសំនៀងខ្សាវៗថា : -ព្រះអង្គទតឃើញស្រាប់ ទូលបង្គំនៅគ្រប់ទិសទី ។ ខ្ញុំចង់រស់នៅគ្រប់ទីកន្លែង ។

ព្រះឥន្ទ្រាអស់សំណើច និងមានព្រះបន្ទូលថា :

- ឯងជាសត្វចំលែកណាស់ ។ តែម្នាក់ៗមានសិទ្ធិរស់នៅតាមចំណូលចិត្ត និងតាមស្ថានភាពរបស់ខ្លួន ។



www.budinst.gov.kh www.elibraryofcambodia.org





www.budinst.gov.kh www.elibraryofcambodia.org

ចាប់ពីពេលនោះមក សត្វលោកទាំងអស់ ចែកដី ចែកទឹក ចែកមេឃគ្នានៅ ។ សត្វខ្លះរត់ប្រសេកប្រសាចពាសពេញព្រៃ ខ្លះហោះហើរពេញមេឃ ខ្លះទៀតហែបហែលក្នុងទឹកទន្លេ សមុទ្រ គ្រប់កន្លែង ។

ឯមនុស្សនាំគ្នាសង់លំនៅដ្ឋាន មានស្រែចំការព័ទ្ធជុំវិញភូមិឋាន យ៉ាងស្រស់បំព្រង ។



www.budinst.gov.kh www.elibraryofcambodia.org






www.budinst.gov.kh www.elibraryofcambodia.org

ចំណែកឯសត្វបង្កួយ វានៅគ្រប់ទីកន្លែង ។ ពេលវានៅលើស្លឹកឈើពណ៌បៃតង ស្បែកវាប្រែពណ៌ជាបៃតងដែរ តែបើវាទំនៅតាមមែកឈើ ស្បែកវាក៏ប្រែពណ៌ដូចមែកឈើនោះទៅ ។

ដូចនេះហើយបានជាបង្កួយមានពណ៌ដូចធម្មជាតិដែលនៅជុំវិញវា ។

តាមលំនាំរឿង "អាហ្វ្រិក"

* រូបបង្កួយក្នុងរឿងនេះ ជាបង្កួយ (Cameleon) នៅតំបន់អាហ្វ្រិក ។ យើងយករូបនេះដោយផ្អែកលើខ្លឹមសាររឿងដែលបញ្ជាក់ពីពណ៌របស់បង្កួយប្រភេទនេះ ។ ហើយយើងសង្ឃឹមថា : អ្នកអានពិតជាស្គាល់បង្កួយរូបអាហ្វ្រិកមិនខាន បន្ថែមលើរូបបង្កួយដែលមាននៅកម្ពុជា ។



www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| VENTE INTERDITE<br>Not for Sale<br>ហាមលក់ | REPRODUCTION INTERDITE<br>No Copy Allowed<br>ហាមថតចម្លងបោះពុម្ព |

www.budinst.gov.kh www.elibraryofcambodia.org